**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**អគ្គនាយកដ្ឋានអប់រំ**
**នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**

# របាយការណ៍ ស្តីពី
# ការប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០១៩
# វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

## សេចក្តីផ្តើម

យោងអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាស្តីពីទិវាជាតិអំណាន។ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយក្រសួងពាក់ព័ន្ធ និងអង្គការដៃគូអភិវឌ្ឍ បានរៀបចំប្រារព្ធពិធីទិវាជាតិអំណានចំនួន៣លើករួចមកហើយ។ ដោយឡែកឆ្នាំ២០១៩ នេះ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងពាក់ព័ន្ធមួយចំនួន និងអង្គការដៃគូអភិវឌ្ឍ បានរៀបចំទិវាជាតិអំណាន១១ មីនា លើកទី៤ ក្រោមប្រធានបទ "**ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត**" មានរយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

គោលបំណងសំខាន់នៃទិវាជាតិអំណានលើកទី៤ រួមមាន បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រីកវប្បធម៌ អរិយធម៌ខ្មែរ។

## I. យុទ្ធវិធី

ដើម្បីឱ្យការប្រារព្ធទិវាជាតិអំណានឆ្នាំ២០១៩ នេះ ប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា បានផ្សព្វផ្សាយ និងជម្រាបជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ក្នុងការអនុវត្តសេចក្តីណែនាំលេខ៤៧អយក.សណន ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ការប្រារព្ធទិវាជាតិអំណាន ឱ្យមានប្រសិទ្ធភាព។ ក្រសួងក៏បានចេញសេចក្តីសម្រេចបង្កើតគណៈកម្មការគ្រប់គ្រងនិងដឹកនាំ គណៈកម្មការបច្ចេកទេសការរៀបចំទិវាជាតិអំណាន ព្រមទាំងប្រកាសព័ត៌មាន និងរៀបចំសន្និសីទសារព័ត៌មានស្តីពី ការប្រារព្ធទិវាជាតិអំណាន ក្រោមប្រធានបទ "**ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត**"។

ក្នុងការបំពេញបេសកកម្មនេះ គណៈកម្មការគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណាន បានសហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងព័ត៌មាន បង្កើតគណៈកម្មការវាយតម្លៃដាក់ពិន្ទុដល់បេក្ខជនប្រកួតប្រជែង ការអានអត្ថបទ សូត្រកំណាព្យ និងការតែងនិពន្ធ ព្រមទាំងសហការជាមួយក្រុមយុវជនស្ម័គ្រចិត្ត ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ មានដូចជា អង្គការយូណេស្កូ បណ្ណាល័យជាតិកម្ពុជា សមាគមបណ្ណារក្សនិងឯកសារវិទូកម្ពុជា គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយពិព័រណ៍សៀវភៅកម្ពុជា អង្គការភ្លែនអន្តរជាតិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ អង្គការSipar អង្គការSVA អង្គការ Room to Read សាលារៀនអន្តរទ្វីបអាមេរិកកាំង ធនាគារជាតិកម្ពុជា ក្នុងការសហការរៀបចំ និងឧបត្ថម្ភ។

## II. សកម្មភាពការប្រារព្ធទិវាជាតិអំណាន១១ មីនា ឆ្នាំ២០១៩

- **ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៩**

កម្មវិធីប្រកួតប្រជែងការអានអត្ថបទ សូត្រកំណាព្យ និងការតែងនិពន្ធ ដើម្បីដណ្តើមជ័យលាភីថ្នាក់ជាតិ លេខ១ លេខ២ និងលេខ៣ លើវិញ្ញាសាទាំង៣នេះ សម្រាប់ការទទួលពានរង្វាន់ **សម្តេចតេជោ ហ៊ុន សែន** ។

១-កម្មវិធីបើកការប្រកួតប្រជែង ការអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ

ក-សមាសភាពគណៈអធិបតី

| | | |
|---|---|---|
| 1.ឯកឧត្តម | **ជ័យ ចាប** | ទីប្រឹក្សារាជរដ្ឋាភិបាល |
| 2.លោកជំទាវ | **ច័ន្ទ ធី** | រដ្ឋលេខាធិការក្រសួងព័ត៌មាន |
| 3.លោកជំទាវ | **ទន់ សាអ៊ីម** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| 4.លោកជំទាវ | **ស៊ឿ សុជាតា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| 5.ឯកឧត្តម | **យ៉ាន់ មូរិន** | ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| 6.លោក | **វ៉ែន សុន** | អនុប្រធានសមាគមអ្នកនិពន្ធខ្មែរ |
| 7.លោកបណ្ឌិត | **ម៉ុក សារ៉ុម** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ |
| 8.លោក | **យឹម សារិន** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| 9.លោក | **យិន យាន** | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ |

10.លោក លោកស្រី ក្រុមការងាររៀបចំទិវាជាតិអំណាន

11.បេក្ខជនប្រកួតប្រជែង ការអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ និងអាណាព្យាបាលបេក្ខជនមកពី២៥ រាជធានីខេត្ត ។

**សរុបអ្នកចូលរួមមាន ១៩១នាក់ ក្នុងនោះស្រី ១០២នាក់។**

**ខ- របាយការណ៍សង្ខេប ស្តីពី វឌ្ឍនភាពនៃកម្មវិធីប្រកួតប្រជែងជ័យលាភីថ្នាក់ជាតិក្នុងកម្មវិធីជាតិអំណាន**

លោក **យិន ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា បានបង្ហាញពីការរៀបចំទិវាជាតិអំណាន៣លើករួចមកហើយ លើកទី១ ឆ្នាំ២០១៦ ក្រោមប្រធានបទ "**បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន**" នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ការប្រារព្ធលើកទី១ យើងមិនទាន់មានការប្រកួតប្រជែងលើវិញ្ញាសាណាមួយ នៅឡើយទេ ដោយគ្រាន់តែ មានការអានអត្ថបទ និងការស្មូតកំណាព្យជាគំរូតែប៉ុណ្ណោះ។ លើកទី២ ឆ្នាំ២០១៧ ក្រោមប្រធានបទ "**អានដើម្បីភាពសុខដុមនៃជីវិត**" នៅវិទ្យាស្ថានជាតិអប់រំ។ ការប្រារព្ធលើកទី២ យើងមានការប្រកួតប្រជែងលើវិញ្ញាសាពីរ គឺ ការអានអត្ថបទ និងស្មូតកំណាព្យ ។ ការប្រារព្ធលើកទី៣ ឆ្នាំ២០១៨ ក្រោមប្រធានបទ "**អំណានជាកំណប់វិជ្ជាមហាសាល**" នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ ការប្រារព្ធលើកទី៣ មានការរៀបចំប្រកួតប្រជែងលើបីវិញ្ញាសា គឺ ការអានអត្ថបទ សម្រាប់សិស្សបឋមសិក្សា (ថ្នាក់ទី៤-៦) ការស្មូតកំណាព្យ សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ(ថ្នាក់ទី៧-៩) និងការតែងនិពន្ធ សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២)។ ដោយឡែកឆ្នាំ២០១៩ នេះ ក្រសួងបានរៀបចំទិវាជាតិអំណានលើកទី៤ ក្រោមប្រធានបទ " **ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត** " ដែលប្រព្រឹត្តទៅរយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី០៨ ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ហើយក៏មានការរៀបចំប្រកួតប្រជែងលើបីវិញ្ញាសា គឺការអានអត្ថបទ សម្រាប់សិស្សបឋមសិក្សា(ថ្នាក់ទី៤-៦) ការស្មូតកំណាព្យសម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) និងការតែងនិពន្ធ សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ(ថ្នាក់ទី១០-១២) ដើម្បីទទួលពានរង្វាន់ " **សម្តេចតេជោ ហ៊ុន សែន** " ដូចឆ្នាំកន្លងទៅដែរ ។

**គ- មតិសំណេះសំណាលរបស់ ឯកឧត្តម ជ័យ ចាប ទីប្រឹក្សារាជរដ្ឋាភិបាល**

ឯកឧត្តមទីប្រឹក្សារាជរដ្ឋាភិបាល មានប្រសាសន៍ទាក់ទងនឹងកម្មវិធីប្រកួតប្រជែងថ្ងៃនេះថា ការប្រកួតប្រជែងយើងមាន៣វិញ្ញាសា គឺការអានអត្ថបទ ការស្មូតកំណាព្យ និងការតែងនិពន្ធ ។ បេក្ខជនត្រូវធ្វើយ៉ាងណា អាន និង ស្មូតបន្លឺសូរឱ្យបានច្បាស់លាស់ និងត្រឹមត្រូវតាមសូររបស់ពាក្យខ្មែរ។ ឧទាហរណ៍ «តាកែវ» ត្រូវបន្លឺសូរ «តា-កែវ» មិនមែន«តា-គែវ»ទេ ។ «ស្រណោះ» មិនមែន « ប្រណោះ» ទេ។ « ស្វាយ » មិនមែន «ឆ្វាយ»ទេ ។ល។ អ្នកស្មូតត្រូវបង្ហាញឱ្យឃើញនូវសំឡេងផ្អែមមានទឹកដមពីធម្មជាតិ និងការតែងនិពន្ធទាល់តែខ្លឹមសារនោះផ្តល់

ប្រយោជន៍ ផលចំណេញ ទើបគេអាន និងមានតម្លៃ។ ឯកឧត្តមបានផ្តាំផ្ញើដល់បេក្ខជន បេក្ខនារីទាំងបីវិញ្ញាសា ត្រូវខិតខំបញ្ចេញឱ្យអស់ សមត្ថភាពផ្ទាល់ខ្លួន ដើម្បីទទួលពានរង្វាន់ដ៏ថ្លៃថ្លា និងកិត្តិយសសម្រាប់ខ្លួនឯង គ្រួសារ សាលារៀន មូលដ្ឋាន និងប្រទេសជាតិយើង។

២-កម្មវិធីប្រកួតប្រជែង ការអានអត្ថបទ ការសូត្រកំណាព្យ និងការតែងនិពន្ធ

**ក-ក្រុមប្រកួតប្រជែង ការអានអត្ថបទ បានប្រព្រឹត្តទៅនៅសាលប្រជុំនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**

ក.១ សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ

| | | |
|---|---|---|
| ១. លោកជំទាវ | **ច័ន្ទ ធី** | រដ្ឋលេខាធិការក្រសួងព័ត៌មាន |
| ២. លោក | **ឃឹម សារិន** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ៣. លោកស្រី | **ម៉ៅ តាន់ណារី** | អនុប្រធាន.កា.រិ.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ៤. លោក | **យ៉េង គំស៊ាន** | អនុប្រធាន.កា.រិ.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ៥. លោកស្រី | **ផាន់ សុជាតា** | មន្រ្តី.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |

ក.២ សមាសភាពបេក្ខជន

បេក្ខជនមកពី២៥ រាជធានី-ខេត្ត មាន២៥ នាក់ ក្នុងនោះស្រី២២ នាក់ និងកំពុងសិក្សានៅថ្នាក់ទី៤ ទី៥ និងថ្នាក់ទី៦ នៃសាលាបឋមសិក្សាចំណោះទូទៅ។

ក.៣ លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកអានអត្ថបទ

- អានអត្ថបទបានលឿន គោរពឃ្លា ល្បះបានត្រឹមត្រូវ
- សំឡេង/សំនៀងច្បាស់ៗ ត្រឹមត្រូវតាមសូររបស់ពាក្យ
- មិនខុសពាក្យ មិនរំលងពាក្យ
- ឥរិយាបថសមរម្យ

**ខ-ក្រុមប្រកួតប្រជែងសូត្រកំណាព្យ** បានប្រព្រឹត្តទៅនៅក្នុងបន្ទប់ប្រជុំនៃអគាររដ្ឋបាលចៅពញាហុក

ខ.១ សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ

| | | |
|---|---|---|
| ១. ឯកឧត្តម | **ជ័យ ចាប** | ទីប្រឹក្សារាជរដ្ឋាភិបាល |
| ២. លោកជំទាវ | **សឿ សុជាតា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តម | **យ៉ាន់ មូរិន** | ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ៤. លោក | **យិន យាន** | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ |
| ៥. លោក | **យូ លក្ខិណា** | អនុប្រធាន.កា.រិ.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ៦. លោក | **ខិន សុតារា** | អនុប្រធាន.កា.រិ.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |

**ខ.២ សមាសភាពបេក្ខជន**

បេក្ខជនមកពី ២៥ រាជធានី-ខេត្ត មាន ២៥ នាក់ ក្នុងនោះស្រី ១៩ នាក់ និងកំពុងសិក្សានៅសាលមធ្យមសិក្សាចំណោះទូទៅ ចាប់ពីថ្នាក់ទី៧ ដល់ទី៩ នៃមធ្យមសិក្សាបឋមភូមិ។

ខ.៣ លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកសូត្រកំណាព្យ

- សូត្រតាមលំនាំបទនៃកំណាព្យ
- ទឹកដមពីរោះក្រអៅក្រអួន
- សំឡេងមិនដាច់ មិនភ្លាត់ ឬ ភ្លាវនាំឱ្យខុសចង្វាក់
- ទឹកមុខ កាយវិការ ទៅតាមបរិយាកាសនៃបទនីមួយៗ

**គ-ក្រុមប្រកួតប្រជែងតែងនិពន្ធ** បានប្រព្រឹត្តទៅនៅបន្ទប់មជ្ឈមណ្ឌលឯកសារ នៃអគាររដ្ឋបាលចៅពញាហុក

គ.១ សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ

១. លោកជំទាវ **ឆន់ សាអ៊ីម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
២. លោក **យិន ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
៣. លោក **ម៉ែន សុន** អនុប្រធានសមាគមអ្នកនិពន្ធខ្មែរ
៤. លោក **ព្រៃ សំបូរ** អនុប្រធាន.ការិ.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
៥. ល.បណ្ឌិត **គួយ សុគាន** អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានជាតិអប់រំ
៦. លោកស្រី **ប៊ី គឹមសែន** អនុប្រធានការិ.មន្ទីរអេយក.រាជធានីភ្នំពេញ

គ.២ សមាសភាពបេក្ខជន

បេក្ខជនមកពី២៥ រាជធានី-ខេត្ត មាន២៥ នាក់ក្នុងនោះស្រី១២ នាក់ និងកំពុងសិក្សានៅសាលាមធ្យមសិក្សាចំណេះទូទៅ ចាប់ពីថ្នាក់ទី១០ ដល់ទី១២ នៃសាលាមធ្យមសិក្សាទុតិយភូមិ។

គ.៣ លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកតែងនិពន្ធ

- អត្ថរូប រចនាបទ ( រង្វាស់កាព្យ ចំណាប់ចួន ភាសាកាព្យ )
- អត្ថន័យ ( ត្រឹមត្រូវតាមប្រធានបទ )
- អត្ថរស ( តម្លៃអប់រំ តម្លៃគុណធម៌ និងតម្លៃសីលធម៌ )
- អត្ថាវិរុទ្ធ

❖ **ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៩**

១-កម្មវិធីសម្ពោធស្តង់និងការតាំងពិព័រណ៍សៀវភៅ

កម្មវិធីកាត់ខ្សែរបូសម្ពោធស្តង់តាំងពិព័រណ៍សៀវភៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងមានការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួង ភ្ញៀវជាតិ អន្តរជាតិ ក្រុមយុវជនស្ម័គ្រចិត្ត ក្រុមការងាររៀបចំទិវាជាតិអំណាន និងអ្នកសារព័ត៌មាន។ ឯកឧត្តមមានប្រសាសន៍ថា ការរៀបចំស្តង់និងតាំងពិព័រណ៍សៀវភៅ មានគោលដៅ ៖

- ការរៀបចំនេះ គឺយកចំថ្ងៃកំណើតរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ក្នុងបំណងដឹងគុណូបការចំពោះព្រះអង្គដែលបានរៀបចំ ប្រមូលចងក្រងជា វចនានុក្រមខ្មែរ ជាលើកដំបូង ។
- លើកកម្ពស់ការអាននៅកម្ពុជា ដូចជាការអានសៀវភៅ ការអានតាមប្រព័ន្ធទូរសព្ទ
- បានបង្កឱកាសឱ្យក្មេងជំនាន់ក្រោយ ស្គាល់អ្នកនិពន្ធជំនាន់មុន។

ដោយឡែកការរៀបចំប្រារព្ធទិវាជាតិអំណាន មានគោលបំណងលើកកម្ពស់អក្សរសាស្ត្រខ្មែរ ការអានភាសាខ្មែរ។ ឆ្លើយតបនឹងចំណុចនេះ ឯកឧត្តមបណ្ឌិតសភាចារ្យ បានសំណូមពរឱ្យសិស្ស និស្សិត ចូលរួមលើកកម្ពស់ភាសាខ្មែរ អានអក្សរសិល្ប៍ បង្កើតឱ្យមានទម្លាប់នៃការអាន និងការសិក្សាពេញមួយជីវិត។

២-ការរៀបចំស្តង់តាំងពិព័រណ៍សៀវភៅ

- ស្តង់តាំងពិព័រណ៍សៀវភៅ សរុបមាន ៦៧ស្តង់
- សកម្មភាពស្តង់ សួនអំណាន និងសួនកុមារ

**ក-សកម្មភាពនៃស្តង់ពិព័រណ៍សៀវភៅ** អតិថិជន សិស្ស និស្សិត និងមហាជនទូទៅ ចូលរួមទស្សនានៃការតាំងពិព័រណ៍សៀវភៅទិញសៀវភៅ និងការលេងល្បែងផ្សេងៗដើម្បីទទួលបានសៀវភៅអានដោយឥតគិតថ្លៃ ។

**ខ-សួនកុមារ** មានការដឹកនាំកុមារគូររូប បត់រូប ផាត់ពណ៌ អានរឿង និងសកម្មភាពផ្សេងៗមួយចំនួនទៀត

**គ-សួនអំណាន** មានការចាក់បញ្ចាំងវីដេអូ ការជួយរកសៀវភៅជូនអ្នកអានតាមតម្រូវការ

ឃ-ទីកន្លែងចែកសៀវភៅ មានសកម្មភាពការងារសំខាន់ៗដូចជា ការអានសេរី, ប្រកួតប្រជែងឆ្លើយសំណួរខ្លីៗ,

ការកំសាន្តទោល ឬជាក្រុម (ល្បងប្រាជ្ញា , ស្វែងរកកំណាប់) ឆ្លើយសំណួរ ដើម្បីពួកគាត់ទទួលបានសៀវភៅ។

**ជារួមក្នុងថ្ងៃបើកសម្ពោធកម្មវិធីពិព័រណ៍ មានអ្នកចូលរួមប្រមាណជា ៣០០០០ នាក់។**

៣-កម្មវិធីប្រកាសជ័យលាភី

**ក-សមាសភាពគណៈអធិបតីភាព និងអ្នកចូលរួម**

១. ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ទាំង៣ វិញ្ញាសា

២. បេក្ខជន បេក្ខនារីទាំង៣ វិញ្ញាសា និងអាណាព្យាបាលរបស់បេក្ខជន មកពី២៥ រាជធានី ខេត្ត សរុបអ្នកចូលរួមមាន ១៩១នាក់ ក្នុងនោះស្រី ១០២នាក់។

**ខ-របាយការណ៍សង្ខេបស្តីពីការប្រឡងអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ**

លោក **ឃិន ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មានប្រសាសន៍រាយការណ៍ថា សកម្មភាពប្រឡងការអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ បានប្រព្រឹត្តដោយរលូនទាំងបីវិញ្ញាសា ដោយមានការត្រួតពិនិត្យ កែលម្អ វាយតម្លៃ ដាក់ពិន្ទុប្រកបដោយភាពយុត្តិធម៌ពីគណៈកម្មការតាមវិញ្ញាសានីមួយៗ។

**គ-ការប្រកាសលទ្ធផលជ័យលាភី វិញ្ញាសាការអានអត្ថបទ**

លោកជំទាវ **ច័ន្ទ ធី** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុវិញ្ញាសាការអានអត្ថបទ មានប្រសាសន៍ថា ការអានត្រូវគោរពទៅតាមឃ្លា ល្បះ អានឱ្យបានត្រឹមត្រូវច្បាស់ មិនខុសពាក្យ មិនរំលងពាក្យ និងឥរិយាបទសមរម្យ។

**តារាងលទ្ធផលបេក្ខជនជ័យលាភី វិញ្ញាសាការអានអត្ថបទ**

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃខែឆ្នាំកំណើត | ថ្នាក់ | មកពីសាលា | ខេត្ត | ម.ភាគ | ចំណាត់ថ្នាក់ |
|---|---|---|---|---|---|---|---|---|
| ១ | ហេង សូនីតា | ស្រី | 25.5.2007 | ៦ | ប.អូរតាពុក | ប៉ៃលិន | 7.90 | ១ |
| ២ | អ៊ីន សុខនាង | ស្រី | 12.4.2007 | ៦ | ប.ប្រាំបីមុំ | កំពង់ស្ពឺ | 7.80 | ២ |
| ៣ | សាន មុន្នីរ័ត្ន | ស្រី | 19.4.2008 | ៦ | ប.ហ.ស អនុវត្ត | កំពង់ចាម | 7.20 | ៣ |

**ឃ-ការប្រកាសលទ្ធផលជ័យលាភី វិញ្ញាសាការស្មូត្រកំណាព្យ**

ឯកឧត្តម **ជ័យ ចាប** ទីប្រឹក្សារាជរដ្ឋាភិបាលនិងជាប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុវិញ្ញាសាស្មូតកំណាព្យ មានប្រសាសន៍ថា មិនមានបេក្ខជនណាម្នាក់ត្រូវបានធ្លាក់ពិន្ទុទេ ហើយពិន្ទុដែលទទួលបានជ័យលាភី លើសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ។

**តារាងលទ្ធផលបេក្ខជនជ័យលាភី វិញ្ញាសាការស្មូតកំណាព្យ**

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃខែឆ្នាំកំណើត | ថ្នាក់ | មកពីសាលា | ខេត្ត | ម.ភាគ | ចំណាត់ថ្នាក់ |
|---|---|---|---|---|---|---|---|---|
| ១ | សុខ ណារី | ស្រី | 03.06.2006 | ៨ | អនុវិ.អភិវឌ្ឍន៍ | កំពង់ឆ្នាំង | 9.29 | ១ |
| ២ | ធួន ដាណុច | ប្រុស | 17.08.2005 | ៧ | វិ.ព្រែកលាប | រាជធានីភ្នំពេញ | 9.04 | ២ |
| ៣ | ម៉ាប់ លិនដា | ស្រី | 03.08.2003 | ៩ | អនុវិ.ជ្រោយស្តៅ | បាត់ដំបង | 8.98 | ៣ |

- បេក្ខជនជ័យលាភីលេខ១ ស្មូតបទពាក្យ៧ មានចំណងជើងថា " **ព្រះគុណម៉ែ** " បែបខមាទោស
- បេក្ខជនជ័យលាភីលេខ២ ស្មូតបទកាកគតិ មានចំណងជើងថា " **ផ្លែផ្កាអំណាន** " បែបពុទ្ធបាតប្រាំឋាន
- បេក្ខជនជ័យលាភីលេខ៣ ស្មូតបទពាក្យ៧ មានចំណងជើងថា " **ឧត្តមភាពជាតិខ្មែរ** " បែបទំនួញនាងពិម្ពា

**ង-ការប្រកាសលទ្ធផលជ័យលាភី វិញ្ញាសាតែងនិពន្ធ**

លោកជំទាវ **ទន់ សារ៉ឹម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ជាប្រធានក្រុមគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំង ការតែងនិពន្ធកំណាព្យ បានបង្ហាញពីលក្ខខណ្ឌវាយតម្លៃដាក់ពិន្ទុជូនដល់បេក្ខជនមានដូចជា ការកំណត់ពេលវេលាក្នុងការតែងនិពន្ធ ការកំណត់ចំនួនល្បះ និងខ្លឹមសារឱ្យប្រមូលផ្តុំចំលើប្រធានបទ " **ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត** " ។

តារាងលទ្ធផលបេក្ខជនជ័យលាភី វិញ្ញាសាតែងនិពន្ធ

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃខែឆ្នាំកំណើត | ថ្នាក់ | មកពីសាលា | ខេត្ត | ពិន្ទុ | ចំណាត់ថ្នាក់ |
|---|---|---|---|---|---|---|---|---|
| ១ | ទៀង ធន | ប្រុស | 23/6/2002 | ១១ | វិ.មេសាង | ព្រៃវែង | 8.75 | ១ |
| ២ | រិន ស៊ាវហ៊ុង | ស្រី | 16/10/2001 | ១២ | វិ.សម្ដេចឪ | តាកែវ | 8.25 | ២ |
| ៣ | ហេង ស៊ីវម៉ា | ប្រុស | 06/3/2002 | ១១ | វិ.បរហេស.ចរិយាវង្ស | កែប | 7.00 | ៣ |

- បេក្ខជនជ័យលាភីលេខ១ តែងកំណាព្យ មានចំណងជើងថា " **ការអានបណ្ដុះវប្បធម៌ការសិក្សាពេញមួយជីវិត**"
- បេក្ខជនជ័យលាភីលេខ២ តែងកំណាព្យ មានចំណងជើងថា " **ផ្លែផ្កានៃអំណាន** "
- បេក្ខជនជ័យលាភីលេខ៣ តែងកំណាព្យ មានចំណងជើងថា " **អំណានជាយានឈានទៅរកជោគជ័យ** "

❖ **ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៩**

**១-ការហាត់សមរបស់បេក្ខជនជ័យលាភី**

សកម្មភាពហាត់សមនាពេលនេះស្ថិតក្រោមអធិបតីភាពលោកជំទាវជាគណៈកម្មការគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណាន។ សកម្មភាពហ្វឹកហាត់សមត្ថភាពអានអត្ថបទ និងសូត្រកំណាព្យ និងការទទួលពានរង្វាន់ជ័យលាភី។

**២-សកម្មភាពស្តង់ពិព័រណ៍សៀវភៅ សួនកុមារ និងសួនអំណាន**

គ្រប់ទីតាំងទាំងអស់មានសកម្មភាពមមាញឹកចាប់ពីម៉ោង៨:០០នាទីព្រឹក ដូចថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៩ដែរ និងមានអ្នកចូលរួមអាន ទិញ ក្នុងទីកន្លែងតាំងពិព័រណ៍សៀវភៅមាន ប្រមាណជាង ២០០០០ នាក់។

❖ **ថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១៩**

ក- សមាសភាពគណៈអធិបតី

១. លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

២. ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា ក្រសួងបរិស្ថាន ក្រសួងរ៉ែ និងថាមពល អាជ្ញាធរសេវនកម្មជាតិ រាជបណ្ឌិតសភាកម្ពុជា ក្រុមប្រឹក្សាជាតិភាសាខ្មែរ ធនាគារជាតិកម្ពុជា បណ្ណាល័យជាតិ ឯកសារដ្ឋានកម្ពុជា មន្ត្រីអប់រំក្រោមឱវាទទីស្ដីការក្រសួងអប់រំ យុវជន និងកីឡា ប្រតិភូអប់រំពី២៥ រាជធានី-ខេត្ត ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ សិស្ស និស្សិត ទាំងគ្រឹះស្ថានសាធារណៈ និងឯកជន សរុបអ្នកចូលរួមប្រមាណជាង ២០០០ នាក់។

**ខ- ការទស្សនាវីដេអូខ្លី ស្ដីពីវឌ្ឍភាពការងារអំណាននៅកម្ពុជាឆ្នាំ២០១៨**

វីដេអូខ្លី ស្ដីពីវឌ្ឍភាពការងារអំណាននៅកម្ពុជាឆ្នាំ២០១៨ ត្រូវបានរៀបចំដោយក្រសួងអយក. សហការជាមួយអង្គការចំនួន១០ ដែលកំពុងធ្វើការលើវិស័យអប់រំ ដើម្បីលើកកម្ពស់ការងារអំណាននៅកម្ពុជា ខ្លឹមសារបង្ហាញពីវឌ្ឍនភាពការងារអំណាននៅកម្ពុជា។

**គ- របាយការណ៍របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

ប្រសាសន៍របស់ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានផ្ដោតលើវឌ្ឍនភាពនៃការរៀបចំទិវាជាតិអំណាន ២០១៦ ដល់ ២០១៩ មានខ្លឹមសារដូចខាងក្រោម៖

- បង្ហាញពីការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជ្រើសរើសយកថ្ងៃទី ១១ ខែមីនា ដែលជាថ្ងៃខែកំណើតរបស់ **សម្ដេចព្រះសង្ឃរាជ ជួន ណាត** ដើម្បីប្រារព្ធទិវាជាតិអំណាននេះឡើងរៀងរាល់ឆ្នាំ ក្នុងគោលបំណងរំឭកដល់វីរភាពរបស់ **សម្ដេចព្រះសង្ឃរាជ** ដែលបានខិតខំតស៊ូ ពុះពារការពារមរតកវប្បធម៌អក្សរសាស្ត្រខ្មែរពីអាណានិគមនិយមបារាំង។

- បន្ទាប់ពីរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់ពេលនៃការរៀបចំប្រារព្ធទិវាជាតិអំណាន ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយក្រសួងពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍមួយចំនួន រៀបចំប្រារព្ធទិវាជាតិអំណាន បានចំនួន៣លើករួចមកហើយ។ នៅឆ្នាំ២០១៩ នេះ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រៀបចំប្រារព្ធទិវាជាតិអំណានលើកទី៤ ស្ថិតក្រោមប្រធានបទ "**ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត**" នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានអ្នកចូលរួមសរុប ៤០០០ នាក់។

**ឃ- ការអានអត្ថបទ និងស្មូតកំណាព្យរបស់ជ័យលាភីលេខ១**

- បេក្ខនារី **ហេង សូនីតា** ជាសិស្សសាលាបឋមសិក្សាអូរតាពុក ខេត្តប៉ៃលិន ជាជ័យលាភីលេខ១ ផ្នែកអានអត្ថបទ បានឡើងអានអត្ថបទ មានចំណងជើងថា " **វិជ្ជាជាទ្រព្យគាប់ប្រសើរ** " ។
- បេក្ខជន **សុខ ណារី** ជាសិស្សអនុវិទ្យាល័យអភិវឌ្ឍន៍ ខេត្តកំពង់ឆ្នាំង ជាជ័យលាភីលេខ១ ផ្នែកស្មូតកំណាព្យ បានឡើងស្មូតកំណាព្យ មានចំណងជើងថា "**ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត**" ជាបទពាក្យប្រាំពីរ ស្មូតបែបខមាទោស ជាស្នាដៃនិពន្ធរបស់បេក្ខជនជ័យលាភីលេខ១ផ្នែកតែងនិពន្ធ **ទៀង ធន** ជាសិស្សវិទ្យាល័យមេសាង ខេត្តព្រៃវែង។

**ង- ពិធីប្រគល់ពានរង្វាន់ សម្តេចតេជោហ៊ុនសែន ដល់បេក្ខជនជ័យលាភី**

បេក្ខជនជ័យលាភីទាំង៩រូប ត្រូវបានទទួលពាន និងរង្វាន់ **សម្តេចតេជោ ហ៊ុន សែន** ពីលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មានដូចខាងក្រោម ៖

**១-ផ្នែកជ័យលាភីផ្នែកអានអត្ថបទ**

- ជ័យលាភីលេខ១ ទទួលបានពានមួយ និងទឹកប្រាក់ចំនួន ៣,០០០,០០០៛
- ជ័យលាភីលេខ២ ទទួលបានពានមួយ និងទឹកប្រាក់ចំនួន ២,០០០,០០០៛
- ជ័យលាភីលេខ៣ ទទួលបានពានមួយ និងទឹកប្រាក់ចំនួន ១,០០០,០០០៛

**២-ផ្នែកជ័យលាភីផ្នែកស្មូតកំណាព្យ**

- ជ័យលាភីលេខ១ ទទួលបានពានមួយ និងទឹកប្រាក់ចំនួន ៤,០០០,០០០៛
- ជ័យលាភីលេខ២ ទទួលបានពានមួយ និងទឹកប្រាក់ចំនួន ៣,០០០,០០០៛
- ជ័យលាភីលេខ៣ ទទួលបានពានមួយ និងទឹកប្រាក់ចំនួន ២,០០០,០០០៛

**៣-ផ្នែកជ័យលាភីផ្នែកតែងនិពន្ធ**

- ជ័យលាភីលេខ១ ទទួលបានពានមួយ និងទឹកប្រាក់ចំនួន ៦,០០០,០០០៛
- ជ័យលាភីលេខ២ ទទួលបានពានមួយ និងទឹកប្រាក់ចំនួន ៥,០០០,០០០៛
- ជ័យលាភីលេខ៣ ទទួលបានពានមួយ និងទឹកប្រាក់ចំនួន ៤,០០០,០០០៛

**ច- ពិធីបំពាក់មេដាយជ័យលាភីកិត្តិយសជូនមន្ត្រីអប់រំ**

ក្នុងកម្មវិធីនេះលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានផ្តល់កិត្តិយសដល់មន្ត្រីអប់រំ មានដូចខាងក្រោម ៖

១-ការបំពាក់មេដាយកិត្តិយស ជូនលោក **បណ្ឌិត វង្ស សុធារ៉ា** សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងការស្រាវជ្រាវអក្សរសាស្ត្របុរាណវិទ្យា(សិលាចារឹក) និងចងក្រងបានជាសៀវភៅចំនួន៣ក្បាលទុកសម្រាប់យុវជនជំនាន់ក្រោយសិក្សាស្រាវជ្រាវ។

២-ការផ្តល់ប្រកាសនីយបត្រ និងរង្វាន់លើកទឹកចិត្ត ជូនសាស្ត្រាចារ្យពីររូប ក្នុងការបកស្រាយប្រធានបទ " បង្ហាញតថភាពសង្គម តាមរយៈស្នាដៃអក្សរសិល្ប៍ រឿងកុលាបប៉ៃលិន និងរឿងផ្កាស្រពោន " មាន៖

- លោក សេក ណាន គ្រូបង្រៀន វិទ្យាល័យហ៊ុន សែន ក្រវ៉ាំ ខេត្តកំពង់ធំ ជាជ័យលាភីលេខ១
- លោកស្រី សេង គឹមអង គ្រូបង្រៀន វិទ្យាល័យហ៊ុនសែនបាគង ខេត្តសៀមរាប ជាជ័យលាភីលេខ២

ឆ- **ប្រសាសន៍សំណេះសំណាលរបស់ លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**

ខ្លឹមសារនៃបទសំណេះសំណាលរបស់លោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី បានបង្ហាញពី ៖

- ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលក្នុងការកំណត់យក ថ្ងៃទី១១ ខែមីនា ដែលជាថ្ងៃខែកំណើតរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ប្រារព្ធទិវាជាតិអំណាននេះ ដើម្បីគោរពដឹងគុណចំពោះវីរភាព ដែលព្រះអង្គបានខិតខំតស៊ូការពារ និងថែរក្សាមរតកវប្បធម៌អក្សរសាស្ត្រខ្មែរ ក្នុងសម័យអាណានិគមនិយមបារាំង។
- ការកោតសរសើរចំពោះក្រសួងអប់រំ យុវជន និងកីឡា ដែលបានខិតខំបំពេញការងារ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការងារកំណែទម្រង់វិស័យអប់រំឱ្យកាន់តែប្រសើរឡើង និងទទួលបានជោគជ័យ ជាបន្តបន្ទាប់ ដូចដែលឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីបានបង្ហាញក្នុងរបាយការណ៍វឌ្ឍនភាពស្រាប់។
- កត់សម្គាល់ឃើញថា ទិវាជាតិអំណានឆ្នាំ២០១៩ នេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់យកប្រធានបទ " **ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត** " ពិតជាប្រធានបទដែលគួរចាប់អារម្មណ៍បំផុត និងមានតម្លៃជាសកល ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានមានប្រសាសន៍កាល ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០២ ថា " **ការកសាងឡើងនូវសង្គមកម្ពុជាមួយដែលមានកោសិកាផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និងមានវប្បធម៌ជ្រៅជ្រះ គ្មានភាពក្រីក្រ គ្មានអនក្ខរកម្ម និងគ្មានជំងឺតម្កាត់ផ្សេងៗ** " ។ **សម្តេចតេជោ** ក៏មានប្រសាសន៍កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០២ ថា " **គ្មានការបង្រៀន គ្មានការអប់រំគឺគ្មានការអភិវឌ្ឍ** " ។
- ក្នុងពេលឆាប់ៗខាងមុខ រាជរដ្ឋាភិបាលនឹងអនុម័តគោលនយោបាយស្តីពីការសិក្សាពេញមួយជីវិតដែលមានចក្ខុវិស័យ ជម្រុញប្រជាជនកម្ពុជាគ្រប់រូបឱ្យទទួលបានឱកាសសិក្សាពេញមួយជីវិត គ្រប់ពេលវេលា គ្រប់ទីកន្លែង ប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណតម្លៃ ដើម្បីរួមចំណែកបង្កើនសេដ្ឋកិច្ច និងសុខដុមជីវិតបុគ្គលនិងសង្គម។
- ទស្សនទាន នៃប្រធានបទនេះ បានគិតគូរដល់ឱកាសទទួលបាន ចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញវិជ្ជាជីវៈ និងនវានុវត្តគ្រប់ផ្នែក គ្រប់វិស័យ ជាពិសេសអក្ខរកម្មបច្ចេកវិទ្យា ដែលសព្វថ្ងៃកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ហើយក៏សមស្របនឹងពាក្យស្លោកមួយចំនួន ដូចខាងក្រោម៖
  - អំណានជាឃ្លាំងចំណេះវិជ្ជា ជាឃ្លាំងប្រាជ្ញា ជាមូលដ្ឋានគ្រឹះនៃចំណេះដឹង
  - អំណានតាមបច្ចេកវិទ្យា ជាវិជ្ជាសម្បទាសតវត្សទី២១
  - អំណានជាប្រភពនៃចំណេះដឹង
  - អំណានជាមាគ៌ាឆ្ពោះទៅរកភាពជោគជ័យក្នុងជីវិត
  - អានច្រើនចម្រើនប្រាជ្ញា គតិជ្រះថ្លា ចំណេះដឹងមហាសាល
  - សៀវភៅជាឃ្លាំង អំណានជាយាន ឈានទៅយកចំណេះដឹង
  - ឪពុកម្តាយអាន កូនអាន យើងទាំងអស់គ្នាអាន
  - អានច្រើន សរសេរច្រើន កើនចំណេះ ដើម្បីការអភិវឌ្ឍ
- ក្នុងសម័យសកលភាវូបនីយកម្ម ដែលក្នុងនោះបញ្ហានយោបាយ សេដ្ឋកិច្ច និងបច្ចេកវិទ្យាកាន់តែវិវឌ្ឍន៍ និងមានភាពស្មុគស្មាញ ការអានតាមមធ្យោបាយអេឡិចត្រូនិក កាន់តែពេញនិយម ដែលត្រូវបានជំនួសការអានតាមសៀវភៅ។ ប្រការនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវមានឆន្ទៈមុតស្រួច និងទស្សនៈវិស័យវែងឆ្ងាយ

ក្នុងការបន្តជំរុញ និងលើកកម្ពស់តួនាទីអំណានក្នុងវិស័យអប់រំ ព្រមទាំងពង្រីកវិសាលភាពឱ្យបានទូលំទូលាយនៅទូទាំងប្រទេស ក្នុងគោលដៅបង្កើនសន្ទុះ នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងលើកកម្ពស់ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា តាមរយៈការបង្កើនប្រសិទ្ធភាព និងគុណភាពនៃការស្រាវជ្រាវ និងអភិវឌ្ឍដែលជាកិច្ចការស្នូល។

- ដើម្បីសហការ បន្តការចូលរួមលើកកម្ពស់ការអាននៅកម្ពុជា ឱ្យកាន់តែផុលផុស និងគាំទ្រដល់ការប្រារព្ធទិវាជាតិអំណាន១១មីនា ឱ្យមានកម្មវិធីកាន់តែសម្បូរបែប ប្រកបដោយគុណភាពនិងប្រសិទ្ធភាព ពិសេសជំរុញស្មារតីប្រជាជនកម្ពុជា ឱ្យបង្កើនការចាប់អារម្មណ៍ ចំពោះការអាន បង្កើតទម្លាប់អាន និងបង្កើនការតែងនិពន្ធ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី** បានអំពាវនាវជូនដល់អ្នកពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងសប្បុរសជន ដូចតទៅ៖

**ទី១-** ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំគោលនយោបាយ ក្របខណ្ឌច្បាប់ លិខិតបទដ្ឋាន និងយន្តការចាំបាច់ ដើម្បីជំរុញការអានសម្រាប់ប្រជាជនគ្រប់រូប និងស្របទៅនៅបរិការណ៍ថ្មីនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

**ទី២-** ក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សា មណ្ឌលសិក្សា ទីវត្តអារាមទាំងអស់ត្រូវបង្កើតកម្មវិធីពាក់ព័ន្ធអំណាន និងស្វែងរកប្រភពសម្រាប់អំណាន ឱ្យកាន់តែសម្បូរបែបនិងមានភាពបត់បែន ឆ្លើយតបនឹងតម្រូវការអ្នកអាន។

**ទី៣-**រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវយកចិត្តទុកដាក់ចូលរួមគាំទ្រ ឱ្យបានខ្លាំងក្លាបន្ថែមទៀត ក្នុងការអភិវឌ្ឍមជ្ឈមណ្ឌលសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងទីកន្លែងសម្រាប់អំណាន។

**ទី៤-**ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកទាំងអស់ រួមមានវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តិបត្រព័ត៌មានរបស់រដ្ឋ និងឯកជន សូមជួយផ្សព្វផ្សាយនិងជួយលើកកម្ពស់ សកម្មភាពអំណាន និងបញ្ជ្រាបឱ្យបានកាន់តែទូលំទូលាយ អំពីសារៈសំខាន់នៃអំណាន ដើម្បីឱ្យប្រជាជនយើងកាន់តែយល់ដឹងឆ្ពោះទៅរក **«ការសិក្សាពេញមួយជីវិត»**។

**ទី៥-** ក្មួយៗជាសិស្ស និស្សិតតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ក្រុមយុវជនទាំងអស់ ត្រូវចូលរួមឱ្យកាន់តែសកម្មក្នុងអំណាន។ ចំណែក បងប្អូនជនរួមជាតិដែលជាមាតាបិតា ឬ អ្នកអាណាព្យាបាលក៏សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនដល់បងប្អូន កូនចៅចូលរួមអាន។

**ទី៦-** ដៃគូអភិវឌ្ឍទាំងអស់ត្រូវបង្កើនកិច្ចសហការ និងពង្រឹងភាពជាដៃគូកាន់តែខ្លាំងថែមទៀត ក្នុងការជួយឧបត្ថម្ភគាំទ្រដល់កម្មវិធីនានា បង្កើតសម្ភារៈ និងធនធានសម្រាប់អាន។

**ឆ- បាឋកថារបស់ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី បានធ្វើបាឋកថាស្ដីពី **"ការសិក្សាអក្សរសិល្ប៍ខេមរនិយម តាមរយៈស្នាដៃអក្សរសិល្ប៍រឿងកុលាបប៉ៃលិន និងផ្កាស្រពោន"** ដោយមានខ្លឹមសារដូចខាងក្រោម ៖

**១-ការរីកចំរើននៃអ្នកនិពន្ធ**

ឯកឧត្តមបណ្ឌិតសភាចារ្យបានកោតសរសើរលើកទឹកចិត្ត ដល់លោកបណ្ឌិត **ខឹង សុធារ៉ា** ក្នុងការសិក្សាស្រាវជ្រាវអក្សរបុរាណខ្មែរ "អក្សរចារឹកលើសិលា" ដែលបានបោះពុម្ពផ្សាយចេញជាសៀវភៅ៣ក្បាលក្នុងរយៈពេលបំពេញការងាររបស់លោក៣០ឆ្នាំ។ នាឆ្នាំក្រោយ យើងនឹងរៀបចំឱ្យមានសន្និសីទជាតិ និងអន្តរជាតិស្ដីពីភាសាខ្មែរ ដើម្បីលើកកម្ពស់ការស្រាវជ្រាវពីភាសាខ្មែរ ឱ្យបានកាន់តែច្រើន ហើយយើងសង្ឃឹមថា នឹងមានអ្នកនិពន្ធច្រើនចូលរួមក្នុងការអភិវឌ្ឍសង្គមខ្មែរ។

ក្នុងសតវត្សទី៨ និងទី៩ យើងមានអ្នកនិពន្ធច្រើន ហើយពេលនោះអក្សរសិល្ប៍ត្រូវបានចារលើសិលាចារឹក និងពីសតវត្សទី១៥-១៨ ភាសាខ្មែរកណ្ដាលត្រូវបានកើតឡើង ដែលមានការប្រើភាសាបាលីបូករួមនឹងភាសា

សំស្រ្កឹត។ ក្នុងឆ្នាំ១៩០៤ យើងមានសាលាបាលី១កន្លែង តែពេលនោះមិនមានអ្នកចូលសិក្សាអ្វីទេ ។ តែនៅឆ្នាំ១៩១៤ យើងមានសាលាបាលីមួយទៀត នៅរាជធានីភ្នំពេញ និងមានសកម្មភាពមកដល់សព្វថ្ងៃ។ ជាក់ស្តែងបច្ចុប្បន្ន មិនទាន់មានអ្នកនិពន្ធណា ដែលតែងនិពន្ធអត្ថបទជាកំណាព្យឱ្យបានវែងច្រើនទំព័រ ដូចរឿងទុំទាវ ជាស្នាដៃអ្នកនិពន្ធជំនាន់មុននោះទេ។

**២-ការបកស្រាយ " ការសិក្សាអក្សរសិល្ប៍ខេមរនិយម"**

រឿងរាមកេរ្តិ៍ អាចតែងនិពន្ធមុនល្បើកអង្គរ ហើយបានជ្រាបចូលទៅក្នុងសង្គមខ្មែរគ្រប់ផ្នែកទាំងអស់ ដូចជាល្ខោនខោល ល្ខោនព្រះរាជទ្រព្យ ដោយមានការពោលបន្ថែមឱ្យមានការស្តាប់បានជាដើម ហើយវត្ថុបំណងក្នុងទិវាជាតិអំណានលើកទី៤នេះ តាមពិតយើងចង់លើកយករឿងរាមកេរ្តិ៍មកបកស្រាយពន្យល់ តែដោយមានការបារម្ភខ្លាចអ្នកចូលរួមពិបាកយល់ ទើបយើងលើកយករឿង កុលាបប៉ៃលិន និងផ្កាស្រពោន មកបកស្រាយពន្យល់វិញ។

អក្សរសិល្ប៍រឿង"**កុលាបប៉ៃលិន**"ជាស្នាដៃនិពន្ធរបស់លោក ញ៉ុក ថែម ក្នុងឆ្នាំ១៩៣៦ និងរឿង "**ផ្កាស្រពោន**" ជាស្នាដៃនិពន្ធរបស់លោក នូ ហាច ក្នុងឆ្នាំ១៩៤៧។ អ្នកនិពន្ធទាំងពីរ ជាអ្នកខេត្តបាត់ដំបង។ ខ្លឹមសារអប់រំសំខាន់ៗរបស់រឿងទាំងពីរមាន៖

ក-រឿង កុលាបប៉ៃលិន បានបង្ហាញពី ៖

- ការតស៊ូ មានភាពរឹងប៉ឹង តួអង្គចៅចិត្រហ៊ានលះបង់ជីវិតដើម្បីស្នេហាស្មោះស្ម័គ្រចំពោះ យុននារី
- ភាពទាន់សម័យ ការនិយាយត្រង់មានជំនាញ និយាយសមហេតុផល មិនជឿលើព្រហ្មលិខិត ជាស្នាដៃប្រាកដនិយម និងតួអង្គ ចៅចិត្រ សមជាកូនប្រុសដើមទ្រូងប្រាំហត្ថ។

ខ-រឿង ផ្កាស្រពោន បានបង្ហាញពី៖

- ការឱ្យតម្លៃលើស្នេហាបរិសុទ្ធ
- ជាវណ្ណកម្មស្នាដៃអក្សរសិល្ប៍ប្រាដកនិយម

គ-សោភ័ណអក្សរសិល្ប៍ទាំងពីររឿង ៖

- ការប្រើពាក្យសំដីងាយយល់
- អត្ថបទមាគ៌ាទៅកាន់អង្គរ ក្នុងរឿងផ្កាស្រពោន
- អក្សរសិល្ប៍ខេមរនិយម ដូចជារឿងទាំងពីរនេះស្ថិតក្នុងសម័យអាណានិគមនិយមបារាំង។

❖ កម្មវិធីពេលរសៀល

កម្មវិធីពេលសៀលនេះ ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯក**ឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំង ឯកឧត្តមបណ្ឌិតសភាចារ្យ ឯកឧត្តម លោកជំទាវ លោក លោកស្រី សិស្សនិស្សិត សរុបប្រមាណចំនួន ២០០០ នាក់។ កម្មវិធីបានប្រព្រឹត្តទៅមានសកម្មភាព និងខ្លឹមសារដូចខាងក្រោម៖

**ក- ការសូត្រកំណាព្យដោយជ័យលាភីលេខ ២**

បេក្ខជន **ជួន ដាណុច** សិស្សវិទ្យាល័យព្រែកលាប រាជធានីភ្នំពេញ ជាជ័យលាភីលេខ២ ផ្នែកសូត្រកំណាព្យ បានឡើងសូត្រកំណាព្យ បទកាកគតិ មានចំណងជើងថា " **ផ្លែផ្កាអំណាន** " បែបពុទ្ធបាតប្រាំហាន ជាស្នាដៃនិពន្ធរបស់បេក្ខជនជ័យលាភីលេខ២ផ្នែកតែងនិពន្ធ បេក្ខនារី **រិន ស៊ាវហ៊ុង** ជាសិស្សវិទ្យាល័យសម្តេចឪ ខេត្តតាកែវ។

**ខ-ការអត្ថាធិប្បាយ ស្តីពី " តថភាពសង្គមតាមរយៈស្នាដៃអក្សរសិល្ប៍រឿងកុលាបប៉ៃលិន និងរឿងផ្កាស្រពោន "**

ក្នុងកម្មវិធីនេះ ការធ្វើបទបង្ហាញពី **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអ្នកសម្របសម្រួលកម្មវិធីដោយ **លោកស្រីបណ្ឌិត យួន វិច្ឆិកា** អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ ព្រមទាំងបានធ្វើអត្ថាធិប្បាយដោយវាគ្មិនជ័យលាភីពីររូបរួមមាន៖

១-លោក សេក ណន គ្រូបង្រៀន វិទ្យាល័យ **ហ៊ុន សែន** ក្រវ៉ា ខេត្តកំពង់ធំ ជាបេក្ខជនជ័យលាភីលេខ១

២-លោកស្រី **សេង គឹមអង** គ្រូបង្រៀន វិទ្យាល័យ **ហ៊ុន សែន**បាគង ខេត្តសៀមរាប ជាបេក្ខនារី ជ័យលាភីលេខ២

ខ្លឹមសារការធ្វើអត្ថាធិប្បាយស្តីពី"តថភាពសង្គមតាមរយៈស្នាដៃអក្សរសិល្ប៍រឿងកុលាបប៉ៃលិន និងផ្កាស្រពោន" មានដូចខាងក្រោម៖

- លោកស្រី **សេង គឹមអង** គ្រូបង្រៀន វិទ្យាល័យ ហ៊ុន សែនបាគង មានយោបល់ថា ៖
  - រឿងផ្កាស្រពោន និងរឿងកុលាបប៉ៃលិន បានកើតឡើងក្នុងសម័យអណានិគមនិយមបារាំង និង បង្ហាញពីទុក្ខសោកទុក្ខលំបាករបស់ស្ត្រី។
  - រឿងកុលាបប៉ៃលិន បង្ហាញពីទុក្ខលំបាករបស់ចៅចិត្រ ភាពស្មោះត្រង់ ការមិនរើសអើងរបស់យុវជន
  - ចៅចិត្រ មាន ចរិតឱនលំទោន ( ខន្តី អត់ធ្មត់ មិនតបត ) ស៊ូស្លាប់ដើម្បីភាពតស៊ូ ( ដើម្បីកូនស្រី ហ្លួងរតនសម្បត្តិ នាងយុន នារី ) ធន្ទះសុភាពរាបសារ ខ្លួនទីពឹងខ្លួន និងឱ្យតម្លៃស្ត្រី។
- លោក **សេក ណន** គ្រូបង្រៀនវិទ្យាល័យ **ហ៊ុន សែន** ក្រវ៉ា ខេត្តកំពង់ធំ មានយោបល់ថា៖

  **លក្ខណៈតថភាពសង្គមទាក់ទងនឹងផ្នត់គំនិត៖** រឿងផ្កាស្រពោន បានបង្ហាញពីនារីម្នាក់ដែលស្រពោន ប ណ្តាលមកពីផ្នត់គំនិតរើសអើងវណ្ណៈរបស់ម្តាយដែលយាយនួន បានផ្តាច់ពាក្យនៅពេលដែលប៊ុនធឿន ធ្លាក់ខ្លួនជាអ្នកក្រ។ រឿងទាំងពីរនេះ បានបង្ហាញពីការរៀនសូត្រមានចំណេះ ជំនាញ មានសីលធម៌ ស្មោះត្រង់ វៃឆ្លាត ការខិតខំដើម្បីទទួលបានជោគជ័យ។
  - ទំនៀមទម្លាប់ ៖ សាច់រឿងទាំងពីរបានបង្ហាញពី កេរមរតកពីឪពុកម្តាយមកកូន
  - ជំនឿ៖ ការទស្សទាយរវាងឆ្នាំរបស់វិជាវី និងណៃសិត ពេលវិជាវីធ្លាក់ខ្លួនឈឺ។
  - ទិដ្ឋភាពសាសនា ៖ គោរពព្រះពុទ្ធសាសនា ដូចជាការស្រោចទឹក និងព្រាហ្មណ៍សាសនា
  - ទិដ្ឋភាពប្រវត្តិ៖
    - និពន្ធនៅក្នុងសម័យអាណានិគមនិយមបារាំង ដូចជាបង្ហាញពី ពិធីបុណ្យជាតិរបស់បារាំង
    - បង្ហាញពីសំលៀកបំពាក់ និងអត្តចរិតខ្មែរនៅក្នុងសម័យក្រោមអាណានិគមនិយមបារាំង។
    - អក្សរសិល្ប៍រឿងផ្កាស្រពោន និងរឿង កុលាបប៉ៃលិន សុទ្ធតែត្រូវបានបើកទំព័រដំបូងក្នុងសម័យ អាណានិគមបារាំង ជាចលនាអក្សរសិល្ប៍ខេមរនិយម ។
  - តថភាពភូមិសាស្ត្រ៖អ្នកនិពន្ធរឿងផ្កាស្រពោន គឺលោក នូ ហាច ជាអ្នកស្រុកកំពង់ព្រះ ខេត្តបាត់ដំបង និង អ្នកនិពន្ធរឿងកុលាបប៉ៃលិន គឺលោក ញ៉ុក ថែម ជាអ្នកស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ហើយ អ្នកនិពន្ធទាំងពីរ បានព៌ណនាសាច់រឿងល្អណាស់ ជាក់លាក់ក្នុងទឹកដីខេត្តបាត់ដំបង ។
- ប្រសាសន៍អន្តរាគមន៍របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បុព្វហេតុនៃការដាក់បញ្ចូលរឿងផ្កាស្រពោន និងកុលាបប៉ៃលិនទៅក្នុងកម្មវិធីសិក្សាដោយសារតែ រឿងទាំងពីរនេះ៖
  - ឆ្លុះបញ្ចាំងពីការតស៊ូ
  - រឿងនេះមានលក្ខណៈអប់រំ និងយើងចង់បានរឿងដែលមានការអប់រំ
  - ចង់ឱ្យយុវជន មានក្តីសង្ឃឹម ឱ្យខិតខំប្រឹងប្រែងដើម្បីអនាគតរបស់ខ្លួន និងសង្គមជាតិ
  - ប្រសិនបើអ្នកមានការអប់រំល្អ នោះអ្នកនឹងទទួលបានភាពភ្លឺស្វាង
  - ការសរសេរក្នុងកម្រិតខ្ពស់ មានការប្រយ័ត្នប្រយែង និងមិនចាញ់រឿងបរទេស ហើយការសរសេរជា ភាសាងាយៗ។ រឿងទាំងពីរ បានអប់រំឱ្យមាន វិជ្ជាសម្បទា ចរិយាសម្បទា និងបំណិនសម្បទា។

**សំណួរពីអ្នកចូលរួម**

**១-សំណួរ ចាន់ សុវណ្ណ** ជាគរុនិស្សិតវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានសួរថា " **រឿងអក្សរ សិល្ប៍ទាំងអស់សុទ្ធតែមានកាអប់រំ ចុះហេតុអ្វីបានជារឿងទាំងនោះមិនលើកយកមកពិភាក្សា បែរជាលើកយកតែ**

**រឿងកុលាបប៉ៃលិន និងរឿងផ្កាស្រពោន តែប៉ុណ្ណោះ ? "** ។

ចម្លើយ ៖ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មានប្រសាសន៍ថា ជាក់ស្តែងថ្នាក់ដឹកនាំក្រសួងចង់លើកយករឿង "រាមកេរ្តិ៍" មកពិភាក្សា តែដោយមានការបារម្ភរឿងការយល់ដឹងរបស់អ្នកចូលរួមពីខ្លឹមសាររឿងនេះ ទើបថ្នាក់ដឹកនាំបានសម្រេចជ្រើសរើសយក រឿង ផ្កាស្រពោន និងកុលាបប៉ៃលិន មកពិភាក្សាវិញ។

**២-សំណួរ គរុនិស្សិត** មកពីវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ឯកទេស គណិតវិទ្យា បានសួរថា **មូលហេតុអ្វីបានជាជ្រើសរើសប្រធានបទស្តីពី «ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត » មកធ្វើជាប្រធានបទពិភាក្សា នាទិវាជាតិអំណាននេះ ?**

**ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មានប្រសាសន៍ថា ដើម្បីឆ្លើយតបទៅនឹងគោលដៅឆ្នាំ២០៣០ របស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងក្លាយជាប្រទេសអភិវឌ្ឍនាឆ្នាំ២០៥០ និងឆ្លើយតបនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងដោយឡែកចំណុចដៅទី៤ ក្រសួងអប់រំ យុវជន និងកីឡា នឹងរក្សាឱ្យបាននូវ គុណភាព សមធម៌ បរិយាប័ន្ន ការសិក្សាពេញមួយជីវិត និងការអប់រំសម្រាប់ទាំងអស់គ្នា ទើបទិវាជាតិអំណានលើកទី៤នេះ ក្រសួងបានកំណត់ប្រធានបទ "**ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត** " ក្នុងគោលបំណងបង្កើនទម្លាប់អាន បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រីកវប្បធម៌ អរិយធម៌ខ្មែរ។

**គ-ការសូត្រកំណាព្យដោយជ័យលាភីលេខ ៣**

បេក្ខនារី **ម៉ាប់ លិនដា** សិស្សអនុវិទ្យាល័យជ្រោយស្តៅ ខេត្តបាត់ដំបង ជាជ័យលាភីលេខ៣ ផ្នែកសូត្រកំណាព្យ បានឡើងសូត្រកំណាព្យ សូត្របទពាក្យ៧ មានចំណងជើងថា "**អំណានជាយានឈានទៅរកជោគជ័យ** " បែបទំនួញនាងពិម្ពា ជាស្នាដៃនិពន្ធរបស់បេក្ខជនជ័យលាភីលេខ២ផ្នែកតែងនិពន្ធបេក្ខជន **ហេង ស៊ីវម៉ា** សិស្សវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែន ចរិយាវង្ស ខេត្តកែប។

**ឃ-ការពិភាក្សាលើប្រធានបទ " វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរក្នុងការលើកកម្ពស់អំណាននៅកម្ពុជា "**

ក្នុងកម្មវិធីពិភាក្សាត្រូវបានសម្របសម្រួលដោយ លោកបណ្ឌិត **ឌី ខាំបូលី** ប្រធាននាយកដ្ឋានគោលនយោបាយនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ និងមានការអញ្ជើញចូលរួមពី៖

១-**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២-លោកស្រីបណ្ឌិត **ប៉ែន សេង្ហារិន** សមាជិកាសមាគមអ្នកនិពន្ធខ្មែរ

៣-លោក **យឹម ច័ន្ទសុអហំ** សមាជិកសមាគមអ្នកនិពន្ធខ្មែរ

ការពិភាក្សាលើប្រធានបទ " វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរក្នុងការលើកកម្ពស់អំណាននៅកម្ពុជា " មានខ្លឹមសារដូចខាងក្រោម ៖

១-**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍ថា មុខងារនិងសកម្មភាពរបស់លោករាល់ថ្ងៃ ជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកស្រាវជ្រាវ និងជាអ្នកនិពន្ធផង។

ចំពោះការបែងចែកពេលវេលាដើម្បីភាពជោគជ័យ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីបង្ហាញដូចខាងក្រោម៖

- ដឹងពីការងារអ្វីដែលត្រូវធ្វើ មានសៀវភៅផ្ទាល់ខ្លួន
- ស្តាប់វិទ្យុក្នុងឡាន ការសរសេរទុកក្នុងសៀវភៅ គឺជាការស្រាវជ្រាវ។ ប្រសិនបើយើងមិនសរសេរដោយខ្លួនយើងទេ នោះការងារមិនជោគជ័យឡើយ។
- ការអាន ការស្តាប់ ដល់ទីកន្លែង ជាពិសេស ពេលត្រឡប់មកការិយាល័យវិញត្រូវសរសេរផង អានផង គិតផង មើលស្ថានភាពជាក់ស្តែង។

ការអានជាកាតព្វកិច្ចផង ជាការស្រាវជ្រាវផង សិស្សានុសិស្សដើម្បីរៀនទាន់គេ ត្រូវតែអាន ប្រឹងប្រែងស្រាវជ្រាវ ។

ការបណ្ដុះទម្លាប់នៃការអានគឺការធ្វើយ៉ាងណាបណ្ដុះឱ្យសិស្សមានទម្លាប់អាន និងចូលចិត្តអានសៀវភៅ ដោយក្នុងស្ថានភាពបច្ចុប្បន្ន យើងនៅខ្វះអ្នកនិពន្ធជាភាសាខ្មែរច្រើន។

ទាក់ទងនឹងការតែងនិពន្ធកំណាព្យ អ្នកនិពន្ធត្រូវមានសិល្បវិធីក្នុងការតែងនិពន្ធ ទាក់ទាញអ្នកអាន គឺត្រូវយល់ពីធម្មជាតិ សច្ចៈ និងតថភាព។ យន្តការគាំទ្រការអាន បន្តការគាំទ្រស្នាដៃនិពន្ធផ្សេងៗរបស់អ្នកនិពន្ធ។ ការសរសេរសៀវភៅ យើងមានវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ជាគោល និងជាស្តង់ដារអក្ខរាវិរុទ្ធ។

២-មតិរបស់ លោកស្រីបណ្ឌិត **ប៉ែន សេដ្ឋារិន** សមាជិកាសមាគមអ្នកនិពន្ធខ្មែរ

អ្នកនិពន្ធត្រូវអានអត្ថសញ្ញាណអ្វីមួយឱ្យបានច្រើនជងនិងច្បាស់លាស់ សម្រាប់ការសរសេរបានល្អ។ អានឱ្យយល់ អានដើម្បីនិពន្ធ ហើយតើយើងនិពន្ធដើម្បីនរណា? ដើម្បីអ្វី ? និងដើម្បីធ្វើអ្វី?

៣-មតិរបស់លោក **យឹម ច័ន្ទសុអហំ** សមាជិកសមាគមអ្នកនិពន្ធខ្មែរ

ដើម្បីបណ្ដុះទម្លាប់អាន យើងត្រូវជ្រើសរើសអត្ថបទដែលត្រូវអាន អាចធ្វើអ្វីបានជាអាទិភាព។ មុនដំបូង យើងត្រូវ ផ្ដល់សេរីភាពដល់ខ្លួនយើង ក្នុងការសម្រេចចិត្តអានឬមិនអាន កុំអានទាំងបែបមិនពេញចិត្ត ដោយការអាន ត្រូវបណ្ដុះទម្លាប់ខ្លួនប្រកបដោយធម្មជាតិ ជ្រើសរើសពេលវេលាដែលត្រូវអាន កុំបង្ខំ ពិសេសកុំធ្វើខ្លួនជាធុងមានទឹកពេញ។

## III. សេចក្តីសន្និដ្ឋាន

សកម្មភាពនៃទិវាជាតិអំណានលើកទី៤ ១១ មីនា ២០១៩ បានដំណើរការយ៉ាងរលូនតាមកម្មវិធីដែលបានគ្រោងទុកនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ ក្នុងការរៀបចំកម្មវិធីទិវាជាតិអំណាននាឆ្នាំនេះ មានការរីកចម្រើនជាងឆ្នាំកន្លងមក ដូចជា៖

១. មានការចូលរួមពីមហាជនគ្រប់ស្រទាប់វណ្ណៈយ៉ាងច្រើនកុះករ

២. ស្តង់ពិព័រណ៍សៀវភៅមានចំនួនច្រើន

៣. អ្នកចូលរួមមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើស្តង់ពិព័រណ៍សៀវភៅនិងការអាន

៤. រយៈពេលប្រារព្ធពិធី មាន០៤ ថ្ងៃ។ អ្នកចូលរួមទាំងអស់ មានចំណាប់អារម្មណ៍ និងសប្បាយរីករាយចំពោះការរៀបចំទិវាជាតិអំណាននេះ ដោយពួកគេបានបង្ហាញភាពយល់ដឹងកាន់ច្បាស់ថែមទៀតអំពី សារៈប្រយោជន៍នៃការអាន ។

ថ្ងៃសុក្រ ១កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ ២០១៩

**បានឃើញ និងឯកភាព**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ~~ស.ភ.~~

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

10.04.2019

**អ្នកធ្វើរបាយការណ៍**

**ម៉ុក វ៉ាស៊ី**